លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ព ក៏ប៉ុន្តែអាចមិនបានកែតម្រូវតាមការលះទេសះ។ លោក-អ្នក ប្រហែ អាចត្រូវមើលបញ្ជាក់លេខនៅក្នុង"សៀវភៅទូរស័ព្ទ" (Telephone Directory)។

HTS 631
KHMER

# សេចក្ដីបញ្ជាមកដល់មាតាបិតា នៃសិស្ស ដែលត្រូវយកឈាមពិនិត្យមើល

**Instructions to Parents Whose Children are to Have a Blood Test**

វេជ្ជបណ្ឌិតសំរាប់កូនអ្នក បានបញ្ជាឲ្យមានការពិនិត្យមើលឈាមរបស់កូនអ្នក ដើម្បីពិនិត្យមើលនូវមេរោគជម្ងឺផ្សេងៗ និង/ឬ ជួយក្នុងគំរោងការព្យាបាលកូនអ្នក។ ខ្ញុំនឹងយកឈាមបន្តិចពី ម្រាមដៃ កែងជើង ឬពីដៃកូនអ្នក ។

**សូមអ្នករក្សា** នូវភាពស្ងប់ស្ងាត់ ដើម្បីកុំឲ្យកូនអ្នកមានការភ័យខ្លាច ។

១-សូមអ្នកអញ្ជើញអង្គុយ ហើយដាក់កូនឲ្យអង្គុយលើជង្គង់របស់អ្នក ។

២-ខ្ញុំនឹងយកខ្សែឃឹត មកចងដៃកូនអ្នក ដើម្បីឲ្យសរសៃឈាមប៉ោងឡើង ។

៣-ខ្ញុំនឹងចាក់ម្រាមដៃឬកែងជើងឬដៃ ហើយវាគ្រាន់តែឈឺមួយពព្រិចភ្នែកតែប៉ុណ្ណោះ។ **កាលណា**ចាក់ហើយ ខ្ញុំនឹងច្របាច់កន្លែងនោះបន្តិច តែវាមិនជា ឈឺខ្លាំងអ្វីទេ ។

៤-ជាសំខាន់ណាស់ដែលកុំឲ្យកូនអ្នករើចុះឡើង។ សូមអ្នកជួយទប់វាឲ្យនៅស្ងៀមហើយកិច្ចនេះក៏នឹងចប់ក្នុងពេលភ្លាមៗដែរ ។ ប្រសិនបើកូនអ្នករើចុះឡើង វាអាចបណ្ដាលឲ្យឈឺកាន់តែខ្លាំង ហើយជួនកាលបណ្ដាលឲ្យយើងត្រូវធ្វើឡើងវិញម្ដងទៀត ។

៥-ក្រោយពីចប់កិច្ចនេះហើយ ខ្ញុំនឹងដោះខ្សែឃឹតចេញ ហើយសូមអ្នកជួយយកម្រាមដៃសង្កត់ ក្រណាត់ជក់ទប់កន្លែងមុតនេះផង ។

**អ្នកមិនត្រូវបើក**មើលចុះឡើង ថាតើនៅចេញឈាមឬអត់នោះទេ។ បន្ទាប់មកខ្ញុំនឹងយកស្បៀមកបិតកន្លែងមុតនោះ ដែលអ្នកអាចដោះចេញនៅពេលព្រលប់នេះ ។

៦-សូមកត់ចុះនូវអាសយដ្ឋានរបស់អ្នកផង ។

សូមអរគុណ ចំពោះការយកចិត្តទុកដាក់របស់អ្នក។ យើងនឹងផ្ញើនូវលទ្ធផលនៃការពិនិត្យមើលនេះទៅវេជ្ជបណ្ឌិតដែលបានបញ្ជូនអ្នកមក ។ **សូមលាសិនហើយ** ៕

REVIEWED September2004
NSWMulticulturalHealthCommunicationService

Translated by the Health Translation Service
NSW Health Department, 1991